21. ឱព្រះវរបិតាអើយ ទូលបង្គំអធិស្ឋានសូមអោយគ្រីស្ទបរិស័ទមានទីជំរកបន្ថែមទៀតនៅក្នុងប្រទេសប្រេស៊ីល ដើម្បីផ្តល់ទៅស្ត្រី និង ក្រុមគ្រួសារដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពាន។ សូមឲ្យកន្លែងទាំងនេះមានសុវត្ថិភាព ជាកន្លែងដែលពួកគេមកស្គាល់ព្រះយេស៊ូវ និង សេចក្តីសុខសាន្ត។ (ទំនុកតម្កើង ២៧:៥)

22. ឱ ព្រះអង្គអើយ សូមប្រទានប្រាជ្ញា និងភាពច្នៃប្រឌិតដល់ក្រុមការងារប្រចាំតំបន់របស់សហរដ្ឋអាមេរិកក្នុងការដែលពួកគេមានបំណងចង់ឈោងចាប់ដល់ស្ត្រីជំនាន់ក្រោយ ដោយជឿជាក់និងមានក្តីសង្ឃឹមលើព្រះយេស៊ូវ។ (ទំនុកតម្កើង ៧៨:៤)

23. ព្រះអម្ចាស់អើយ សូមផ្តល់តួនាទីដែលល្អដល់ស្ត្រីដែលកោតខ្លាចទ្រង់នៅអាមេរិកឡាទីន និងតំបន់ការ៉ាបៃនឡើង ដើម្បីអោយពួកគេបានធ្វើការដឹកនាំកិច្ចបម្រើនៅ TWR ក្នុងព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹម។ (ម៉ាថាយ ៩:៣៧)

24. យើងសូមលើកព្រះនាមព្រះបិតាឡើង សូមអោយក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៃអង្គការ TWR នៅ Bonaire អោយពួកគេបានពេញដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ ដើម្បីឱ្យពួកគេនាំយកសេចក្តីពិត និង ការលើកទឹកចិត្តដល់ស្ត្រីនៅជុំវិញពួកគេផងដែរ។ (១ថែស្សា ៥:១១)

25. ព្រះជាម្ចាស់អើយ នៅពេលដែលប្រទេសវេណេហ្ស៊ូអេឡាប្រឈមមុខនឹងភាពអសន្តិសុខសេដ្ឋកិច្ច សូមអនុញ្ញាតឱ្យស្ត្រីនៅទីនោះមានប្រាជ្ញាក្នុងការប្រើប្រាស់ថវិការបស់ពួកគេ និង មានអាហារសម្រាប់គ្រួសាររបស់ពួកគេគ្រប់គ្រាន់។ (ទំនុកដំកើង ៣២:៨)

26. ព្រះអម្ចាស់អើយ វាគឺជាបំណងចិត្តរបស់ក្រុមការងារនៅប្រទេសប៉ារ៉ាហ្គាយ ក្នុងការធ្វើការដោយមានប្រាជ្ញា ការអត់ធ្មត់ សេចក្តីស្រឡាញ់ ក្នុងការបម្រើទ្រង់ និងក្លាយកូនប្រុសស្រីដែលស្តាប់បង្គាប់ដែលអនុញ្ញាតអោយទ្រង់ប្រើតាមព្រះទ័យទ្រង់។ (រ៉ូម ១២:១១)

27. ព្រះដ៏ជាអម្ចាស់ យើងសូមសរសើរព្រះនាមទ្រង់ចំពោះមនុស្សស្មោះត្រង់នៅប្រទេសកាណាដា ដែលអធិស្ឋានជារៀងរាល់ខែសម្រាប់តម្រូវការដែលបានសរសេរចុះនៅក្នុងប្រតិទិនអធិស្ឋាន។ (កូឡូស ៤:២)

28. ឱព្រះវរបិតាអើយ ក្នុងពេលដែលមានការបែងចែកនយោបាយ ភាពអវិភាព និងការមានមោទនភាពនៅក្នុងប្រទេសប្រេស៊ីល កូនទាំងអស់គ្នាស្រែករកការរួបរួមតែមួយនៃពួកអ្នកជឿ។ សូមព្រះរាជបុត្រាទ្រង់យាងមក និង ធ្វើជាអ្នកសម្រុះសម្រួលនៅក្នុងដួងចិត្តរបស់យើង។ (ម៉ាថាយ ៥:៩)

후원안내

국민은행 851-01-0003-724 북방선교방송

최초 입금 후 사무실로 연락 주시기 바랍니다

# Women of Hope

## Prayer Calendar

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 65,000នាក់



**2023. 2.**

**ការអធិស្ឋានសម្រាប់ស្ត្រីនៅអាមេរិកខាងជើងនិងខាងត្បូង**

កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង។ ភីលីព 4:6

ការអធិស្ឋាន គឺជាអំណោយទាន គឺជាការអញ្ជើញពីព្រះ ដើម្បីឲ្យយើងមករកទ្រង់ក្នុងគ្រប់កាលៈទេសៈទាំងអស់ក្នុងជីវិតរបស់យើង។

ការអធិស្ឋានគឺជាការឆ្លើយតបពីយើងទៅចំពោះទ្រង់ ដែលបញ្ជាក់ពីសេចក្តីជំនឿរបស់យើងទៅលើទ្រង់ ពីអំណាច និង សេចក្តីសប្បុរសរបស់ទ្រង់។ ទ្រង់បានអញ្ជើញយើងអោយចូលរួមក្នុងទំនាក់ទំនងដែលយើងអាចរៀន និង ស្គាល់ទ្រង់យ៉ាងមានភាពស្និទស្នាល។

**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 phkorea@twrk.or.kr

**អធិស្ឋានសំរាប់................**

1. ព្រះដ៏មានមហិទ្ធិឫទ្ធិ សូមជួយអោយព័ន្ធកិច្ច TWR Women of Hope នៅ Bonaire មានការរីកចម្រើន និងអភិវឌ្ឍទៅមុខ។ សូមទ្រង់ផ្តល់ប្រាជ្ញាដល់តួនាទីរបស់ពួកគេនីមួយៗ ក្នុងការដឹកនាំមនុស្សទៅរកទ្រង់។ (ទំនុកតម្កើង៣៧:៥)

2. បិតាអើយ សូមបញ្ជូនកូនស្ងួនភ្ងារបស់ទ្រង់អោយចេញទៅកំសាន្ត និងលើកទឹកចិត្តដល់មនុស្សចាស់នៅប្រទេសអ៊ុយរូហ្គាយ ដែលប្រឈមមុខនឹងភាពឯកោ និងការបាក់ទឹកចិត្ត។ (ទំនុកតម្កើង៧១:៩,១៨)

3. ព្រះអម្ចាស់អើយ យើងអធិស្ឋានសូមឱ្យអ្នកដឹកនាំនៅក្នុងប្រទេសប្រេស៊ីល បាននឹកចាំ និងផ្តល់ការថែទាំដ៏ល្អត្រឹមត្រូវសម្រាប់ក្រុមស្ត្រីដែលចាំបាច់ទទួលការព្យាបាល។ (១ធីម៉ូថេ២:១-២)

4. យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានអនុញ្ញាតឱ្យស្ត្រីនៅក្នុងពន្ធនាគាររបស់ប្រទេសប៉ារ៉ាហ្គាយដែលមាននាមជា semi-free មកចូលរួមការសិក្សាព្រះគម្ពីរ និងការ បណ្តុះបណ្តាល នៅ TWR ជាមួយព័ន្ធកិច្ចស្ត្រីក្នុងក្តីសង្ឃឹម។ (ទំនុកដំកើង ៩០:១៧)

5. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញាដល់ភាពជាដៃគូថ្មីរបស់ព័ន្ធកិច្ច TWR នៅប្រទេសCanada ដែលចាប់ផ្តើមនៅឆ្នាំ2023នេះ។ សូមឱ្យការផ្សាយដំណឹងល្អអំពីទ្រង់ និងការនិយាយរបស់ពួកគេ មានការប៉ះពាល់ទៅកាន់ជីវិតរបស់ស្ត្រីនៅជុំវិញពិភពលោក និងនាំពួកគេឱ្យស្គាល់ទ្រង់ផងដែរ។ (អេសាយ ៥២:៧)

6. កូនសូមអរព្រះគុណទ្រង់ ដែលស្ត្រីនៃប្រទេសអ៊ុយរូហ្គាយ បានរកឃើញព័ត៌មាន និងទទួលបានការលើកទឹកចិត្ត និងសេចក្តីសង្គ្រោះតាមរយៈកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម។ (យ៉ូហាន ៣:១៦)

7. ព្រះអម្ចាស់អើយ សូមឲ្យក្រុមប្រចាំតំបន់នៅសហរដ្ឋអាមេរិក បានស្វែងរកទ្រង់ដោយសេចក្តីស្រឡាញ់ និង ការស្តាប់បង្គាប់ជាមុនសិន។ សូមទ្រង់ដឹកនាំពួកគេ ហើយបង្ហាញគ្រប់ទាំងជំហានដែលពួកគេឈានក្នុងការបម្រើទ្រង់នៅក្នុងព័ន្ធកិច្ចនីមួយៗផងដែរ។ (រ៉ូម ១២:២)

8. បិតាអើយ សូមផ្តល់កម្លាំង ការលើកទឹកចិត្ត និងការងារល្អដល់ម្តាយនៅលីវក្នុងប្រទេសអាមេរិកឡាទីន ដែលតស៊ូរាល់ថ្ងៃដើម្បីមើលថែក្រុមគ្រួសាររបស់ពួកគេ។ (និក្ខមនំ ១៥:២)

9. ឱព្រះអម្ចាស់អើយ យើងអធិស្ឋានថា ស្ត្រីនៅប្រទេសប្រេស៊ីលរបស់យើងនឹងស្វែងរកទ្រង់ និងស្រេកឃ្លានរកទ្រង់ផងដែរ។ (ទំនុកតម្កើង ៤២:១-២)

**Phum Roung Chak, Sangkat Kok Kleang,**

**Khan Sen Sok, Phnom Penh**

**ភូមិរោងចក្រ សង្កាត់គោកឃ្លាង ខ័ណ្ឌសែនសុខរាជធានីភ្នំពេញ )**

**Tel: 092 60 60 51 /086 60 60 56**

10. ព្រះអម្ចាស់អើយ សូមប្រទានពរឱ្យក្រុមការងាររបស់យើងនៅប្រទេសប៉ារ៉ាហ្គាយ ក្នុងការប្រើប្រាស់ប្រតិទិនអធិស្ឋានរបស់ពួកគេ ដោយប្រើបច្ចេកវិទ្យាថ្មី។ ហើយក៏សូមអរគុណចំពោះក្រុមអធិស្ឋាននៅអេស្ប៉ាញ និងអាល្លឺម៉ង់ ដែលប្រើប្រាស់សេចក្តីអធិស្ឋាននេះក្នុងការចូលទៅរកទ្រង់ជារៀងរាល់ថ្ងៃ។ (១ថែសាឡូនិច ៥:១៦-១៨)

11. ព្រះបិតាអើយ យើងអធិស្ឋានសុំឱ្យកម្មករចំណាកស្រុករាប់ពាន់នាក់ ដែលមកនៅប្រទេសអ៊ុយរូហ្គាយដែលកំពុងស្វែងរកអនាគតដ៏ល្អប្រសើរ នឹងស្វែងរកទ្រង់ដើម្បីបំពេញតម្រូវការរបស់ពួកគេ សូមទ្រង់ប្រទានពរដល់ពួកគេ។ (ភីលីព ៤:១៩)

12. ឱ ព្រះដ៏មានមហិទ្ធិឫទ្ធិ សូមឲ្យក្មេងស្រី និងស្ត្រីនៅប្រទេសហ្គាតេម៉ាឡា បានទទួលស្គាល់ទ្រង់ បានរកឃើញអត្តសញ្ញាណពិតប្រាកដរបស់ពួកគេនៅក្នុងទ្រង់ ហើយដឹងថានៅក្នុងទ្រង់ ពួកគេនឹងទទួលបានការស្រឡាញ់ ការអភ័យទោស និងការផ្តល់តម្លៃ។ (កាឡាទី ៣:២៦-២៨)

13. ព្រះវរបិតាអើយ យើងសុំទ្រង់ប្រទានកម្លាំងដល់ស្ត្រីគ្រប់រូបនៅក្នុងទីក្រុង Bonaire ដែលតែងតែមានអារម្មណ៍ថានឿយហត់។ (អេសាយ ៤០:២៩)

14. ឱ ព្រះដ៏ជាម្ចាស់អើយ ទ្រង់គឺសព្វព្រះទ័យឱ្យស្ត្រីគ្រប់ជំនាន់បានស្គាល់ និងធ្វើតាម ទ្រង់។ សូមទ្រង់ចាត់តាំងថ្នាក់ដឹកនាំនិងអ្នកស្ម័គ្រចិត្តជំនាន់ក្រោយដើម្បីអោយពួកគេបានធ្វើការជាមួយនឹង ក្រុមការងារTWRនីមួយៗនៅជំនាន់នេះផងដែរ។ (យ៉ូអែល ១:៣)

15. ឱព្រះវរបិតាអើយ ទូលបង្គំអធិស្ឋានសម្រាប់យុវនារីនៅប្រទេសអាហ្សង់ទីន សូមអោយពួកគេបានការដើរយ៉ាងជិតស្និទ្ធជាមួយនឹងទ្រង់។សូមបញ្ជូនអ្នកបម្រើរបស់ទ្រង់អោយចេញទៅដើម្បីអោយដំណឹងល្អរបស់ទ្រង់បានលឺដល់ពួកគេ។ (យ៉ូហាន ១០:១០)

16. ព្រះអម្ចាស់អើយ យើងសូមសរសើរព្រះនាមព្រះអង្គដែលសៀវភៅ **Hope Encounters**ត្រូវបានប្រើប្រាស់នៅក្នុងក្រុមស្ត្រីជាច្រើន នៅក្នុងប្រទេសប្រេស៊ីល។ សូមឲ្យព្រះវិហារ និងមនុស្សច្រើនទៀតបានស្គាល់ និង ប្រើប្រាស់សៀវភៅនោះផងដែរ។ (ទំនុកតម្កើង១១៩:១០៥)

17. ព្រះជាម្ចាស់អើយ យើងសរសើរតម្កើងព្រះអង្គ ដែលក្រុមប៉ារ៉ាហ្គាយរបស់យើងបានទទួលបានកំណើនឡើងទៅដល់ 25% ក្នុងការផ្សព្វផ្សាយទៅកាន់ស្ត្រីផ្សេងទៀត ហើយអាចអោយពួកគេនាំដំណឹងល្អពីព្រះយេស៊ូវដល់អ្នកដទៃផងដែរ។ (១យ៉ូហាន ៥:៤)

18.សូមរំដោះស្ត្រីវ័យក្មេងនៅអ៊ុយរូហ្គាយចេញពីការបំផ្លិចបំផ្លាញនៃអំពើបាប និង ឧក្រិដ្ឋកម្ម បិតាអើយ ដែលពួកគេអាចមានការពាក់ព័ន្ធនឹងការប្រើប្រាស់ និងលក់គ្រឿងញៀនផងដែរ។ (ទំនុកតម្កើង ៦៨:២០)

19. ឱ ព្រះវរបិតាអើយ យើងអធិស្ឋានសម្រាប់ក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសប៉ារ៉ាហ្គាយដើម្បីអោយពួកគេបង្កើតក្រុមស្ត្រីដោយមានភាពវ័យឆ្លាតនិងមានក្តីស្រឡាញ់ចំពោះស្ត្រីដែលធ្លាប់ស្នាក់នៅពន្ធនាគារ និង បន្តមានទំនាក់ទំនងល្អផងដែរ។ (១កូរិនថូស ៣:៩)

20. ព្រះអម្ចាស់អើយ សូមប្រទានប្រាជ្ញា គំនិតច្នៃប្រឌិត និង ការណែនាំពីព្រះវិញ្ញាណរបស់អ្នកដល់ក្រុមអ៊ុយរូហ្គាយ នៅពេលពួកគេសរសេរអត្ថបទសម្រាប់កម្មវិធី Women of Hope ។ (កាឡាទី ៥:២៥)